# ការជម្រាបដំណឹងខ្លីៗជូនសហគមន៍ពាក់ព័ន្ធនឹងច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិចឡើងវិញ

CITY OF LONGBEACH RECOVERY ACT

| ថវិកាសរុប | ការចំណាយមកពេលនេះ: | ចំនួនកម្មវិធី |
|---|---|---|
| $296.9 លាន | $232.33 លាន | 85 |

## ព័ត៌មានត្រឹមខែ ឧសភា ២០២៤

### អំពីច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិច

កាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២១ ក្រុមប្រឹក្សាក្រុង បានអនុម័តច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិចឡើងវិញ ដែលប្រការនេះធ្វើឲ្យក្រុងឡុងប៊ិច ក្លាយជាអ្នកឈានមុខគេដំបូងគេក្នុងចំណោមក្រុងធំៗ ដែលអនុម័តកម្មវិធីស្តារឡើងវិញពីវិបត្តិនៃជំងឺកូវីដ-១៩ ដោយប្រើប្រាស់មូលនិធិពីថ្នាក់ជាតិ គឺមូលនិធិច្បាប់សង្គ្រោះអាមេរិក (ARPA)។ ច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិចឡើងវិញនេះ បានផ្ដល់មូលនិធិឧបត្ថម្ភកម្មវិធីធំៗ ដូចជាសេដ្ឋកិច្ច សុខភាពសាធារណៈ និងកម្មវិធីប្រចាំឆ្នាំសម្រាប់ពលរដ្ឋឡុងប៊ិច ម្ចាស់អាជីវកម្ម និងកម្មករ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយវិបត្តិនោះ។ ជារួមគំនិតផ្ដួចផ្ដើមនេះ វិនិយោគធ្វើឲ្យក្រុងឡុងប៊ិចមានភាពល្អប្រសើរ និងរីកលូតលាស់ខាងសេដ្ឋកិច្ច។

### សហគមន៍មានសុខភាពល្អ និងសុវត្ថិភាព




### សេដ្ឋកិច្ចងើបឡើងវិញ




### ធានាអនាគតក្រុងយើង



# ព័ត៌មានអំពីផលចំណេញដល់សហគមន៍

CITY OF LONGBEACH RECOVERY ACT

## សហគមន៍មាន សុខភាពល្អ និងសុវត្ថិភាព






## សេដ្ឋកិច្ច ងើបឡើងវិញ



### មណ្ឌលរៀនសូត្ររបស់សហគមន៍

“ខ្ញុំពេញចិត្តក្នុងការទៅមណ្ឌលរៀនសូត ព្រោះបុគ្គលិកនៅទីនោះជួយពួកយើងធ្វើកិច្ចការសាលា និងខ្ញុំពេញចិត្តដែលបុគ្គលិកជួយរៀបចំផែនការសកម្មភាពឲ្យពួកយើង ដូចជាផ្នែករបាំដាំដើម។

**- អ្នកចូលរួមកម្មវិធី**

“ជាបុគ្គលិកពេញម៉ោង ដែលធ្វើការនៅជួរមុខ ខ្ញុំពេញចិត្តមជ្ឈមណ្ឌលរៀនសូត្រនេះណាស់ ដោយគេមានផ្តល់សកម្មភាពងាយស្រួល! ខ្ញុំជាម្តាយដែលមើលថែកូនតែម្នាក់ឯង។ ជាការលំបាកណាស់ ក្នុងការរកកម្មវិធីឯណាដែលអត់បង់ប្រាក់ ១០០% បែបនេះ ហើយកម្មវិធីនេះធ្វើសម្រាប់កុមារទៅទៀត។ កាលក្នុងវិបត្តិ ខ្ញុំស្ទើរបាត់បង់អ្វីៗគ្រប់យ៉ាងអស់ទៅហើយ។ ប៉ុន្តែ ខ្ញុំបានធូរច្រើនណាស់ ដោយមានការជួយជ្រោមជ្រែងពីបុរស និងស្ត្រី ដែលនៅជួយយ៉ាងស្ងៀមស្ងាត់ទាំងនេះ។ ខ្ញុំឲ្យឈ្មោះអ្នកទាំងនេះ ថាជាវីរបុរសសម្រាប់ឆ្នាំ ២០២០-២០២១ របស់ខ្ញុំ!”

**- ឪពុកម្តាយអ្នកចូលរួមកម្មវិធី**

“ឧទ្យាននេះ បានជួយខ្ញុំ និងគ្រួសារខ្ញុំ តាមរយៈកម្មវិធី និងសកម្មភាពរបស់ពួកគាត់។ កូនប្រុសខ្ញុំ សប្បាយដែលបានទៅចូលរួមកម្មវិធីក្រោយម៉ោងសាលា។ ខ្ញុំជឿទុកចិត្តបុគ្គលិក។ ពួកគេយកចិត្តទុកដាក់យើងណាស់ និងមានចិត្តមេត្តា និងដឹងគ្រប់ព័ត៌មាន និងកម្មវិធីថ្មីៗ។ កូនប្រុសខ្ញុំសូមអរគុណដល់អ្នកប្រឹក្សាយោបល់ទាំងអស់ ដែលចំណាយពេលវេលាលេងកំសាន្ត និងបង្កើតកម្មវិធីឲ្យកូនខ្ញុំបានសប្បាយ”។

**- ឪពុកម្តាយអ្នកចូលរួមកម្មវិធី**

### ស្វែងរកអាជីពក្នុងក្រុមហ៊ុនអវកាស SPACE BEACH

"ខ្ញុំជិតបានដំណឹងគ្រប់សព្វហើយ ដែលថាខ្ញុំចង់ទៅធ្វើការផ្នែកឧស្សាហកម្មអវកាស"។

**- អ្នកចូលរួមកម្មវិធី**

“កាលពីមុន ពិន្ទុក្នុងថ្នាក់រៀនរបស់ខ្ញុំ គឺទាបដល់ថ្នាក់ខ្ញុំអស់សង្ឃឹម។ ខ្ញុំតែងតែបរាជ័យគ្រប់រឿងដែលខ្ញុំចង់ធ្វើ។ ប៉ុន្តែឥឡូវនេះ ខ្ញុំគិតថា ខ្ញុំអាចសម្រេចគោលដៅទៅតាមក្តីប្រាថ្នារបស់ខ្ញុំ”។

**- អ្នកចូលរួមកម្មវិធី**